នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Dec-2012, 15:49
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ
**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង
**ថ្ងៃដាក់** : ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២
**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញា
**ភាសាដើម** : អង់គ្លេស

## ចំណាត់ថ្នាក់ឯកសារ

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ
**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:** សាធារណៈ/Public
**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**
**ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:**
**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**
**ហត្ថលេខា:**

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹង "សំណើរបស់ ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចមិនកោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យកែប្រែនីតិវិធីក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី"

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក អាង ឧត្តម |
| ពេជ អង្គ | លោក Michael G.KARNAVAS |
| Elisabeth SIMONNEAU FORT | លោក គង់ សំអុន |
| | លោកស្រី Anta GUISSÉ |
| | លោក Arthur VERCKEN |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១- នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ មេធាវីការពារក្តី ខៀវ សំផន (“មេធាវីការពារក្តី”) បានដាក់សំណើមួយពាក់ព័ន្ធនឹងបែបបទនៃការសួរដេញដោលភាគីដើមបណ្តឹងរដ្ឋប្បវេណី និងដែលបានចោទប្រកាន់ថាបានរំលោភសិទ្ធិរបស់ ខៀវ សំផន ក្នុងការទទួលបាននូវសវនាការដោយត្រឹមត្រូវ[1] (“សំណើ”)។ ដើម្បីជាដំណោះស្រាយ មេធាវីការពារក្តីចង់ឲ្យអង្គជំនុំជម្រះសាលាដំបូង (១) កោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី (Chau Ny) និង (២) កែប្រែសេចក្តីសម្រេចលើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងការសួរដេញដោលរបស់ភាគីដែលបានប្រើប្រាស់រហូតដល់ពេលនេះ ក្នុងសំណុំរឿង ០០២[2]។

២- សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបដូចតទៅ។ សហព្រះរាជអាជ្ញាគាំទ្រចំពោះសំណើនេះដើម្បីកោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ប៉ុន្តែមិនយល់ស្របថា មានការរំលោភណាមួយទៅលើសិទ្ធិរបស់ ខៀវ សំផន ឡើយ ព្រមទាំងជំទាស់នឹងសំណើសុំកែប្រែលំដាប់លំដោយនៃការសួរដេញដោលភាគីដើមបណ្តឹងរដ្ឋប្បវេណី។

# II. អំណះអំណាង

## ក. សំណើគាំទ្រឲ្យកោះហៅឡើងវិញដើមបណ្តឹងរដ្ឋប្បវេណី TCCP-187, ចៅ នី

៣- សហព្រះរាជអាជ្ញាគាំទ្រចំពោះសំណើសុំឲ្យកោះហៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី មកបង្ហាញខ្លួនឡើងវិញ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ព័ត៌មាននៅក្នុងកំណត់ហេតុរបស់ ចៅ នី អំពីការឈឺចាប់ទាំងឡាយ បាននាំឲ្យភាគីចង់សួរដេញដោលបន្ថែម[3] និងថាបើដូច្នេះ មានផលប្រយោជន៍នៃយុត្តិធម៌ក្នុងការកោះហៅគាត់ឡើងវិញ។

[1] **E250** សំណើសុំឲ្យពិនិត្យឡើងវិញនូវសេចក្តីសម្រេចបដិសេធការកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យកែប្រែបែបបទក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ៧ ធ្នូ ២០១២ (បានជូនដំណឹងនៅថ្ងៃទី៧ ធ្នូ ២០១២) (ចាប់ពីនេះតទៅហៅថា “សំណើ”)។

[2] **E250** សំណើ ត្រង់កថាខណ្ឌ២៣-២៥។

[3] និយាយឲ្យចំ ចៅ នី បានបញ្ជាក់ថា គាត់អាចមានព័ត៌មានបន្ថែមទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ ខៀវ សំផន។ **E1/146.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៣ វិច្ឆិកា ២០១២, ទំព័រ៤៣។

## ខ. លំដាប់លំដោយនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីមិនចាំបាច់កែប្រែទេ

៤- សហព្រះរាជអាជ្ញាជំទាស់នឹងសំណើសុំឱ្យកែប្រែលំដាប់លំដោយនៃការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី សន្និដ្ឋានថាការកែប្រែដូច្នេះមិនមែនជាលក្ខខណ្ឌតម្រូវដើម្បីការពារសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវរបស់ជនជាប់ចោទទេ។ សហព្រះរាជអាជ្ញាទទួលស្គាល់ថា ព័ត៌មានដែលមាននៅក្នុងកំណត់ហេតុថ្លែងពីការឈឺចាប់ផ្សេងៗមិនមែនជាកម្មវត្ថុនៃការសួរដេញដោលតទល់ទេ អាចមិនទទួលបានតម្លៃភរនីយភាពទាក់ទងនឹងអំពើ និងសកម្មភាពរបស់ជនជាប់ចោទ នៅពេលសក្ខីកម្មនោះត្រូវបានសួរដេញដោលឡើយ[4]។ ដូចលោក Abdulhak បានកត់សម្គាល់នៅក្នុងតុលាការនៅពេលបញ្ហានេះបានកើតឡើងថា "សម្រាប់លោកចៅក្រមត្រូវធ្វើការថ្លឹងថ្លែងពីតម្លៃភរនីយភាពចំពោះសេចក្ដីថ្លែងណាមួយដែលបានផ្ដល់នៅក្នុងតុលាការ"[5]។

៥- ទោះជាយ៉ាងនេះក៏ដោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគួរតែអនុញ្ញាតឱ្យភាគីធ្វើសំណើសុំឱ្យសួរដេញដោលបន្ថែមដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ប្រសិនបើសេចក្ដីថ្លែងទុក្ខវេទនាឈឺចាប់កើតជាបញ្ហាដែលភាគីមួយ ឬច្រើន ជឿអំពីការថ្លែងបន្ថែម។ បន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចតាមឆន្ទៈរបស់ខ្លួនអំពីថាតើការសួរដេញដោលបន្ថែមទៀត គួរអនុញ្ញាតដែរ ឬទេ។ លោកចៅក្រម Lavergne ហាក់ដូចជាបានផ្ដល់ការយល់ព្រម នូវវិធីនេះដោយលោកបានថ្លែងថា៖ "*ប្រសិនបើសេចក្ដីថ្លែងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនឹងកើតបញ្ហាថាតើមេធាវីការពារក្ដីមួយណាចង់សួរសំណួរ។ នោះតាមពិត យើងគួរបានលឺសំណើពីមេធាវីការពារក្ដីចំពោះផល់ប៉ះពាល់នោះ ហើយយើងអាចផ្ដល់ឱកាសឱ្យមេធាវីការពារក្ដីនោះ.*"[6]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សេចក្ដីថ្លែងណាមួយអំពីការរងទុក្ខវេទនាដែលត្រូវការតាំងសំណួរបន្ថែមតាមរយៈនីតិវិធីនេះ គួរតែត្រូវបានពិចារណាទៅលើភ័ស្ដុតាងជាមួយនឹងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពីមុន។

[4] សូមមើលវិធាន៨៧(២) នៃវិធានផ្ទៃក្នុង។

[5] **E1/146.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៣ វិច្ឆិកា ២០១២, ទំព័រ៩៣។

[6] ឯកសារលេខ **E1/146.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២, ទំព័រទី១០៥។

៦- នៅទីបញ្ចប់ សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា មេធាវីការពារក្តីបាននិយាយបញ្ចៀតបញ្ចៀង ទៅរក "សិទ្ធិទាមទាមួយ ដើម្បីនិយាយសម្តីចុងក្រោយបង្អស់"[7] ទាក់ទងនឹងការតាំងសំណួរដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនានា។ ខណៈដែលវាពិតណាស់ថា ពាក់ព័ន្ធជាមួយដីកាដំណោះស្រាយ វិធានផ្ទៃក្នុងបានតម្រូវថា"នៅគ្រប់ករណីទាំងអស់ ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទ ត្រូវតែមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានចុងក្រោយជានិច្ច"[8] វិធានផ្ទៃក្នុងមិនបានតម្រូវដូចគ្នានេះទេ ទាក់ទង ទៅនឹងការតាំងសំណួរដេញដោលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី។ តាមការពិតយោងតាមវិធាន៩១ *ស្ទួន* "ប្រធានអង្គជំនុំជម្រះសាលាដំបូងត្រូវកំណត់លំដាប់លំដោយដែលចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងភាគីនានាដទៃទៀត មានសិទ្ធិតាំងសំណួរទៅកាន់ជនជាប់ចោទ សាក្សី អ្នកជំនាញ និងដើម បណ្តឹងរដ្ឋប្បវេណី"។ ហេតុនេះលំដាប់លំដោយក្នុងការសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីនានា ដែលធ្វើឡើងដោយប្រធាន គឺស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចនៃបុព្វសិទ្ធិរបស់គាត់ដែលមានចែងនៅក្នុង វិធានផ្ទៃក្នុង។

### គ. សេចក្តីសង្កេតទាក់ទងនឹងសិទ្ធិរបស់ ខៀវ សំផន ក្នុងការនៅស្ងៀមមិនឆ្លើយតប

៧- ទាំង នៅក្នុងតុលាការ អម្លុងពេលនៃការថ្លែងឆ្លើយឆ្លងគ្នាទៅវិញទៅមក និងក៏ដូចជានៅក្នុងសំណើ សេចក្តីយោងត្រូវបានធ្វើឡើង ដោយផ្អែកទៅលើការដកហូតមកវិញរបស់ជនជាប់ចោទនូវសិទ្ធក្នុងការ នៅស្ងៀមមិនឆ្លើយ ដែលត្រូវបានផ្តល់ឲ្យគាត់ដោយអនុលោមតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាយល់ឃើញថា ជាការចាំបាច់ដើម្បីធ្វើការកត់សម្គាល់ថាដូចលោក Abdulhak បាន ថ្លែងនៅក្នុងតុលាការថា "លោក ខៀវ សំផន មិនបានអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការនៅស្ងៀមមិនឆ្លើយ នោះឡើយ ប៉ុន្តែផ្ទុយទៅវិញ បានសម្រេចចិត្តជ្រើសយកការឆ្លើយ នៅដំណាក់កាលពិសេសណាមួយ នៅក្នុងសវនាការ និងសម្រេចនៅពេលពិសេសណាមួយដែលនៅពេលនោះគាត់អាចឆ្លើយនឹងសំណួរ នានា នៅក្នុងដំណាក់កាលក្រោយមកទៀតនៃដំណើរការនីតិវិធីសវនាការ"[9]។ កាលពីមុនសហព្រះរាជ អាជ្ញាបានលើកឡើងអំពីបញ្ហានេះ និងអំពីផលវិបាករបស់វានៅចំពោះមុខអង្គជំនុំជម្រះ[10] ហើយ

---

[7] ឯកសារលេខ **E250** សំណើ កថាខណ្ឌទី១៥។

[8] វិធាន៩៤ នៃវិធានផ្ទៃក្នុង។

[9] ឯកសារលេខ **E1/146.1** ប្រតិចារឹកសវនាការលើអង្គសេចក្តី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២, ទំព័រទី៩៣។

[10] ឯកសារលេខ **E174** សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការ បដិសេធមិនឆ្លើយតបទៅនឹងសំណួរនៅក្នុងសវនាការ, ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២។

ជនជាប់ចោទខ្លួនឯង បានទទួលស្គាល់ថាខ្លួនមិនបានទទូចសុំឲ្យប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះទេ តែផ្ទុយទៅវិញសូមឆ្លើយតបទៅនឹងសំណួរនៅក្នុងកាលបរិច្ឆេទក្រោយមកទៀត ដោយបានថ្លែងថា៖ "ខ្ញុំនឹងឆ្លើយជាយថាហេតុទៅនឹងរាល់សំណួរទាំងអស់"[11]។

## ឃ. សេចក្តីសង្កេតពាក់ព័ន្ធនឹងសំណួររបស់ ខៀវ សំផន

៨- មេធាវីការពារក្តីបានលើកឡើងចោទប្រកាន់ថា អន្តរសកម្មភាពរបស់លោកប្រធានជាមួយនឹងជនជាប់ចោទ តែមិនជាមួយនឹងមេធាវីការពារក្តីរបស់ជនជាប់ចោទនោះ គឺបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីដ៏ត្រឹមត្រូវ។ ទោះបីជាមេធាវីការពារក្តីពុំបានស្នើសុំនូវដំណោះស្រាយណាមួយពាក់ព័ន្ធនឹងចំណុចនេះក៏ដោយ ក៏សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា តាមវិធាន ចៅក្រមទាំងឡាយរបស់អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិតាំងសំណួរដេញដោល ដល់ជនជាប់ចោទ ហើយលោកប្រធានមានសិទ្ធិតាំងសំណួរដេញដោលដល់ជនជាប់ចោទ ជាជំនួសឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលលោកប្រធានធ្លាប់បានធ្វើជាមួយឈ្មោះ ចៅ នី ដូច្នោះ[12]។ ស្រដៀងគ្នានេះដែរ តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង ប្រធានតុលាការមានអំណាចតាំងសំណួរដេញដោលដោយផ្ទាល់ដល់ជនជាប់ចោទ[13]។ នៅពេលដែល ខៀវ សំផន បានបញ្ជាក់ថាគាត់មិនមានបំណងឆ្លើយតបទៅនឹងសំណួររបស់លោកប្រធានទេនោះ លោកប្រធានក៏លែងតាំងសំណួរដេញដោលដល់រូបគាត់ដែរ[14]។ ដូច្នេះ ការរំលោភទៅលើសិទ្ធិរបស់ ខៀវ សំផន គឺពុំបានកើតឡើងនោះទេ។

---

[11] ឯកសារលេខ **E1/146.1** ប្រតិចារឹកសវនាការលើអង្គសេចក្តី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២, ទំព័រទី៩៥។

[12] វិធាន៩០ នៃវិធានផ្ទៃក្នុង។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង, ឆ្នាំ២០១២, មាត្រា៣២៨ ("Le président interroge l'accusé et reçoit ses declarations")។

[14] ឯកសារលេខ **E1/146.1** ប្រតិចារឹកសវនាការលើអង្គសេចក្តី, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២, ទំព័រទី៩៨។

III. **សេចក្ដីសន្និដ្ឋាន**

៩- យោងតាមមូលហេតុនានាដូចបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាស្នើដោយគោរពដល់អង្គជំនុំជម្រះសូមឲ្យកោះហៅឡើងវិញដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ចៅ នី , សូមឲ្យបដិសេធសំណើនោះចោល ដែលធ្វើឲ្យខូចដល់លំដាប់លំដោយតៗគ្នានៃការតាំងសំណួរដេញដោល ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងសូមឲ្យធ្វើការពិចារណាលើសេចក្ដីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញា។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |